# អរិយធម៌អាសានតេ (Asante civilization)

នៅសតវត្សទី១៧ នៃគ.ស. មានតំបន់អរិយធម៌ដ៏សំខាន់មួយកកើតឡើងនៅក្នុងទ្វីបអាហ្វ្រិកខាងលិច ហើយត្រូវបានគេស្គាល់ថាជា តំបន់ Gold Coast (ឆ្នេរមាស)។ បច្ចុប្បន្នជាប្រទេសហ្គាណា(Ghana)។[១] តំបន់នោះ ត្រូវបានគេដឹងថាជាទីតាំងនៃក្រុមមនុស្សដែលមានឈ្មោះថា អាកាន។ Gold Coast គឺជាផ្លូវពាណិជ្ជកម្មដ៏សំខាន់មួយនៅដើមស.វ.ទី ១៧ និងនៅក្នុងតំបន់ទ្វីបអាហ្វ្រិកខាងលិច ដែលគ្រប់គ្រង អាណាចក្រ នៃអរិយធម៌អាសានតេ[២] (រូបលេខ១)។

នៅកំឡុងស.វ.ទី១៧ជដែលនេះ អាសានតេ គឺចាប់ផ្តើមរីកចម្រើននៅតំបន់ Kumasi ដែលជាសំបុកនៃរ៉ែមាស។ គួរបញ្ជាក់ដែរថា នៅសម័យនោះ ពួកអឺរ៉ុប គឺបានមករកមាសនៅក្នុងតំបន់អាហ្វ្រិក ជាពិសេសនៅក្នុងតំបន់ Kumasi ដែរ។ នេះគឺជាហេតុដែលគេហៅថា Gold Coast ដែលសំដៅលើប្រទេសហ្គាណា។ នៅឆ្នាំ១៧៥០នៃគ.ស. អាសានតេ គឺជាអាណាចក្រដែលមានឥទ្ធិពលជាងគេនៅក្នុងតំបន់អាហ្វ្រិកខាងលិច ដែលដឹកនាំដោយស្តេច Osei Tutu។ នៅអំឡុងពេលការដឹកនាំដោយស្តេច Osei Tutu អាណាចក្រនេះមានវិសាលភាពទឹកដីចាប់ពីតំបន់ភាគកណ្តាលនៃប្រទេសហ្គាណា(Ghana) តុងហ្គូ(Tongo) និងរហូតដល់ប្រទេស កូតឌីវ័រ (Côte d'Ivoire)។ អាសានតេ គឺអរិយធម៌ និងអាណាចក្រដ៏មានឥទ្ធិពលនៅក្នុងស.វ.ទី១៨នៃគ.ស. និងមុននៃសម័យអាណានិគមអង់គ្លេស ។

តំបន់ Kumasi មានទីតាំងស្ថិតនៅខាងត្បូងនៃប្រទេសហ្គាណា និងមានចម្ងាយប្រមាណជាង ២៥០គីឡូពីរាជធានីនៃប្រទេសហ្គាណា។ សព្វថ្ងៃនេះ ក្រុមជនជាតិអាកាននៅតែបន្តរស់នៅក្នុងទីក្រុង Kumasi នេះ និងឃើញមានសំណង់តាមបែបប្រពៃណីរបស់អរិយធម៌

[១] Art of the Asante Kingdom | Essay | The Metropolitan Museum of Art | Heilbrunn Timeline of Art History (metmuseum.org)

[២] Ashanti Empire/ Asante Kingdom (18th to late 19th century) • (blackpast.org)

អត្ថបទដោយ៖ អេង តុលា

អាសានតេ ដែលធ្វើផ្ទះអំពីដីឥដ្ឋ និងឈើ ជាដើម។[៣] រវាងឆ្នាំ 1960 និង 1970 សំណង់ទាំងនោះត្រូវបានទិញដោយ Ghana Museums and Monuments Board (GMMB) ហើយត្រូវបានកំណត់ថាជាសម្បត្តិបេតិកភណ្ឌជាតិនៃប្រទេសហ្គាណា និងអង្គការយូណេស្កូ។ សំណង់អាគារទាំងនោះបានក្លាយជាតំបន់ទេសចរណ៍ជាតិ និងអន្តរជាតិនៃប្រទេសហ្គាណា និងមានការរៀបចំថែរក្សាសម្រាប់ការអភិវឌ្ឍន៍នៃអរិយធម៌អាសានតេ។[៤] គម្រោងនេះ គឺគាំទ្រដោយអង្គការមូលនិធិកប្រាសាទពិភពលោក World Monument Fund។ តាមរយៈការសិក្សាផ្នែកបុរាណវិទ្យានៅក្នុងតំបន់នេះ អ្នកបុរាណវិទូបានរកឃើញនូវវត្ថុអំពីលោហធាតុជាច្រើន ជាពិសេសអំពីមាស សម្រាប់ធ្វើការជួញដូរជាមួយពួកអឺរ៉ុប។ ការរកឃើញនៃវត្ថុតាងទាំងនោះបានបង្ហាញអំពីឥទ្ធិពលនៃអរិយធម៌នេះ ដោយសារតែក្នុងសម័យកាលនោះពួកអឺរ៉ុបចូលមកគ្រប់គ្រងលើអាណាចក្រផ្សេងៗ លើកលែងតែអាសានតេនៅមិនទាន់ស្ថិតក្រោយចំណុះរបស់ពួកអឺរ៉ុប (រូបលេខ២)[៥]។

មនុស្សក្នុងអរិយធម៌នេះមានជំនាញក្នុងការផលិតវត្ថុសិល្បៈ អំពីមាស និងក្រណាត់តាមទម្រង់ប្លែកៗ តែមានបច្ចេកទេសខ្ពស់ ជាពិសេសសំណង់ស្ថាបត្យកម្មនៅក្នុងទីក្រុង Kumasi (រូបលេខ៣-៧)។

សរុបមកអរិយធម៌ ឬអាណាចក្រអាសានតេ គឺត្រូវបានដួលរលំបន្ទាប់ពីស្តេច Osei Tutu ត្រូវបានសុគតនៅដើមស.វ.ទី១៨ និងមានការឈ្លានពានពីសំណាក់អរិយធម៌ដ៏ទៃទៀតជាពិសេស ជនជាតិអឺរ៉ុបដែលមករុករករ៉ែមាសនៅក្នុងទ្វីបអាហ្វ្រិកខាងលិចនេះ។ អរិយធម៌នេះមានជីវិតប្រហែលជាង១ស.វ. ពោល គឺចាប់ពីស.វ.ទី១៨ រហូតដល់ពេលដែលចក្រភពអង់គ្លេសដាក់អាណានិគមនៅចុងស.វទី១៩នៃគ.ស។[៦]

[៣] https://whc.unesco.org/en/list/35

[៤] https://www.wmf.org/project/asante-traditional-buildings

[៥] Ashanti Empire/ Asante Kingdom (18th to late 19th century) • (blackpast.org)

[៦] https://www.britannica.com/topic/Asante

អត្ថបទដោយ៖ អេង តុលា







រូបលេខ១ ២ ៖ ផែនទីនៃអរិយធម៌អាសានតេ និងក្រុងKumasi

ប្រភព៖ blackpast.org

អត្ថបទដោយ៖ អេង តុលា





រូបលេខ៣&៤ ៖ សំណង់អាគារនៃអរិយធម៌អាសានតេ

ប្រភព៖unesco.org





រូបលេខ៥&៦ &៧ ៖ វត្ថុអំពីមាស និងក្រណាត់នៃអរិយធម៌អាសានតេ

ប្រភព៖metmuseum.org



## ឯកសារយោង

https://www.wmf.org/project/asante-traditional-buildings
Ashanti Empire/ Asante Kingdom (18th to late 19th century) • (blackpast.org)
https://www.britannica.com/topic/Asante
www.unesco.org

អត្ថបទដោយ៖ អេង តុលា